## សាររបស់លោកអភិបាល អូលីវីយេ
## អំពីព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា និងមរណសាក្សីកម្ពុជា
## តាំងគោក ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

បងប្អូនជាទីស្រឡាញ់!

នៅពេលនេះជាពេលវេលាដើម្បីអធិដ្ឋាន ជាពេលវេលាថ្វាយខ្លួនទៅព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា នៅមុខអាសនៈសក្ការៈបូជាដែលយើងបានថ្វាយ។ ថ្ងៃនេះ យើងបានថ្វាយអភិបូជាលើគ្រែដែលធ្លាប់មានអភិបូជារួមគ្នារបស់លោកអភិបាល ឆ្មារ សាឡាស់ ជាលោកអភិបាលជនជាតិខ្មែរដំបូងគេបង្អស់ ដែលទទួលអគ្គសញ្ញាតែងតាំងជាអភិបាល នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលទីក្រុងភ្នំពេញនាំឲ្យប្រជាជនគ្រប់រូបត្រូវចេញពីទីក្រុងភ្នំពេញ ហើយនៅក្នុងនោះមានលោកអភិបាល ឆ្មារ សាឡាស់ មានលោកឪពុក ឆ្មារ សាឡឹម មានលោកឪពុក សម្រើន និងមានគ្រីស្តបរិស័ទយើងជាច្រើនរួមជាមួយប្រជាជនយើងមួយចំនួនធំបានចេញធ្វើដំណើរទៅគ្រប់ទិសនៃប្រទេសកម្ពុជា។ ប៉ុន្តែ មួយក្រុមនេះបានធ្វើដំណើរដល់តាំងគោកខេត្តកំពង់ធំ ហើយបានចូលនៅក្នុងក្រុមចល័តដែលណែនាំឲ្យលោក ឆ្មារ សាឡាស់ អាចទៅពីកន្លែងមួយទៅកន្លែងមួយ។ នៅពេលគាត់ជួបជាមួយគ្រីស្តបរិស័ទម្នាក់គាត់អាចញញឹម ជូនកាលធ្វើសញ្ញាតិចតួចដើម្បីឲ្យព្រះពរ។ នៅតាំងគោកនេះ គាត់បានធ្វើពលកម្មនៅក្នុងសម័យខ្មែរក្រហម និងគាត់ខិតខំរហូតដល់គាត់អស់ជាតិទឹកនៅក្នុងខ្លួន ហើយនៅពេលនោះគាត់ទទួលមរណភាពក្នុងឆ្នាំ១៩៧៧ នៅវត្តតាំងគោក។ នៅពេលលោក ឆ្មារ សាឡាស់ ស្លាប់យើងបានរកឃើញគម្ពីរដ៏តូចមួយដែលបានណែនាំឲ្យនឹកឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់សំខាន់ណាស់។ ទោះបីនៅក្នុងសម័យខ្មែរក្រហមដែលគេហាមជាដាច់ខាត កុំឲ្យមានសៀវភៅផ្សេងៗ សៀវភៅដែលទាក់ទងនឹងសាសនា ជាពិសេសសរសេរជាភាសាបរទេស។ ប៉ុន្តែ គាត់បានខិតខំថែរក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងប្រហែលប៉ុន្មានដងប៉ុន្មានសា ពួកគាត់ទាំងបីនាក់ (លោក ឆ្មារ សាឡាស់ លោក ឆ្មារ សាឡឹម និងលោក សម្រើន) បានអង្គុយលើគ្រែនេះមិនមែនដើម្បីហូបបាយ ប៉ុន្តែដើម្បីថ្វាយសក្ការបូជានិងទទួលនំ ដែលជាព្រះកាយព្រះគ្រីស្តដែលផ្តល់ជីវិតអស់កល្បជានិច្ច។

នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៥ ព្រះសហគមន៍កម្ពុជាបានបើកតុលាការជាផ្លូវការ ដើម្បីសូមឲ្យសន្តអាសនៈទទួលស្គាល់មរណសាក្សីនៃប្រទេសកម្ពុជា មានលោកអភិបាល ឆ្មារ សាឡាស់ លោកអភិបាល ទេព អុឹម និងមានសហការី១៣នាក់ផ្សេងទៀតដូចជា៖ លោក សាឡឹម

លោក សម្រើន បងស្រីលីឌី លោកឪពុក ប៉ាជ្រេ លោកឪពុក រ៉ាប៉ុង និងគ្រីស្តបរិស័ទមួយចំនួន ដែលទទួលមរណភាពនៅសម័យដ៏ពិបាកហ្នឹង។

ដូច្នេះ នៅពេលនេះខ្ញុំសូមឲ្យបងប្អូនចូលរួមជាមួយព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា ដែលបង្ហាញខ្លួនដល់កូនក្មេង៣នាក់នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩១៧។ នៅពេលនោះ ព្រះនាងម៉ារីមានពាក្យនិយាយទៅកូនក្មេង ហើយជាពិសេសមានពាក្យអាថ៌កំបាំងចំនួនបី រហូតដល់ឆ្នាំ២០០០ សម្តេចប៉ាប យ៉ូហានប៉ូលទី២ បានណែនាំឲ្យពិភពលោកបានដឹងអំពីអាថ៌កំបាំងទាំងបីនៃទីក្រុងហ្វាទីម៉ា។ ថ្ងៃនេះ យើងនឹករឭកដល់សម្តេចប៉ាប យ៉ូហានប៉ូលទី២ ដែលមានគេបាញ់នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៨១ ត្រូវនឹងថ្ងៃបុណ្យព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា គេបាញ់នៅមុខវិសាលវិហារសន្តសិលានៃបូរីវ៉ាទីកង់។ តាមពិតគ្រាប់ដែលគេបាញ់សម្តេចប៉ាប ខុសតែមួយមីលីម៉ែត្រតែប៉ុណ្ណោះនឹងចូលដល់បេះដូង ដែលអាចសម្លាប់សម្តេចប៉ាប។ នេះហាក់បីដូចជាដៃរបស់ព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា បានណែនាំឲ្យគ្រាប់នេះវៀចបន្តិចកុំឲ្យសម្លាប់សម្តេចប៉ាប។ ហេតុនេះហើយ សម្តេចប៉ាបបានយកគ្រាប់ដែលបាញ់ព្រះអង្គទៅដាក់នៅក្នុងមកុដរបស់ព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា។

នៅពេលលោកឪពុកលីគាត់នៅជាយុវជន ជានិស្សិតទេវវិទ្យាល័យនៅឆ្នាំ១៩៩៨ គាត់បានធ្វើដំណើរជាមួយលោកឪពុកអូមៃ ទៅចំការទៀងដើម្បីសួរសុខទុក្ខលោកគ្រូ ជៀង ដែលជាគ្រីស្តបរិស័ទថ្មីៗ ហើយនៅពេលនោះគេយករូបចំលាក់ព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាមួយមកជាមួយដែរ។ នៅពេលនោះ លោកឪពុកលី ជាមួយលោកអូមៃ បានធ្លាក់នៅក្នុងស្រែប៉ុន្តែអត់មានគ្រោះថ្នាក់ធំ ដោយសារព្រះនាងម៉ារីការពារថែរក្សា។ ដូច្នេះព្រះនាងម៉ារីនេះបាននៅចំការទៀងយូរឆ្នាំដែរ ក្រោយមកខ្ញុំផ្ញើទៅដល់ព្រះសហគមន៍ថ្មីគឺនៅព្រៃកប្បាស ថ្ងៃនេះយើងបានខ្ចីដើម្បីឲ្យព្រះនាងម៉ារីនៅជាមួយយើង។ លោកឪពុកលី នឹករឭកដល់ការត្រាស់ហៅរបស់គាត់ច្រើន ហើយខ្ញុំជឿថាថ្ងៃនេះយើងមានយុវជនមួយចំនួនដែលថា **"ខ្ញុំចង់បម្រើព្រះសហគមន៍ដូចលោកឪពុកលី ដូចលោក ឆ្មារ សាឡាស់ លោក សាឡឹម លោក សម្រើន ដើម្បីបន្តប្រកាសដំណឹងល្អនៅលើទឹកដីរបស់យើង"**។

ថ្ងៃនេះ ខ្ញុំអញ្ជើញបងប្អូនរួមជាមួយព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា ឲ្យយើងយកពេលដើម្បីយកព្រះកាយជាអាទិភាពនៅក្នុងជីវិតរបស់យើង។ ឲ្យយើងយល់ថា យើងត្រូវតែតាំងព្រះកាយព្រះគ្រីស្តដើម្បីបូជាជីវិតរបស់យើងរួមជាមួយព្រះជាម្ចាស់។ ឲ្យយើងយកពេល ដើម្បីផ្ញើជីវិតរបស់យើងទាំងស្រុងទៅលើព្រះបេះដូងព្រហ្មចារិនីព្រះនាងម៉ារី និងជាពិសេសឲ្យយើងទៅជាសាក្សីនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ ព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា បានអញ្ជើញពិភព

លោកទាំងមូលឲ្យកែប្រែចិត្តគំនិត។ នៅសម័យសង្គ្រាមពិភពលោកលើកទី១ បានណែនាំឲ្យមនុស្សលោកភ័យខ្លាចណាស់ ប៉ុន្តែសព្វថ្ងៃយើងដូចជាបានចូលនៅក្នុងសង្គ្រាមពិភពលោកលើកទី៣ម្យ៉ាងដោយសារជំងឺកូវីដ១៩។ ដូច្នេះ ខ្ញុំជឿថាសម្រាប់យើងដែលជាគ្រីស្តបរិស័ទ សម្រាប់យើងដែលជាព្រះសហគមន៍កាតូលិកនៅក្នុងពិភពលោក ជាពេលវេលាដើម្បីកែប្រែចិត្តគំនិតដើម្បីរួមជាមួយព្រះនាងម៉ារីណែនាំឲ្យយើងទៅជាមនុស្សថ្មី ឲ្យយើងកសាងជីវិតរបស់យើងសាជាថ្មី ដោយទទួលការលើកលែងទោសពីព្រះជាម្ចាស់ដែលជាព្រះបិតា ដើម្បីផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គ។

បពិត្រព្រះអម្ចាស់ជាព្រះបិតា យើងខ្ញុំអរព្រះគុណព្រះអង្គដែលបានប្រទានមរណសាក្សីដើម្បីណែនាំឲ្យជំនឿរបស់យើងខ្ញុំរឹងមាំ។ ដូច្នេះ នៅពេលនេះយើងខ្ញុំសូមផ្ញើជីវិតរបស់យើងខ្ញុំទាំងស្រុង តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់ដល់មរណសាក្សីទាំងអស់ ដើម្បីឲ្យពួកលោកបំភ្លឺជីវិតរបស់យើងខ្ញុំ ដើម្បីណែនាំឲ្យយើងខ្ញុំជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា មានជំនឿរឹងមាំ មានសេចក្តីសង្ឃឹមជានិច្ច និងចេះស្រឡាញ់គ្នាទៅវិញទៅមក។ យើងខ្ញុំទូលអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាអម្ចាស់យើងខ្ញុំ។

ដូច្នេះ នៅពេលនេះខ្ញុំយកព្រះនាងម៉ារីទៅលើអាសនៈដ៏ពិសិដ្ឋនេះ និងយើងអធិដ្ឋានរួមជាមួយគ្នា រួមជាមួយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ។ ពាក្យអធិដ្ឋានដែលខ្ញុំអធិដ្ឋាននៅពេលនេះ ជាពាក្យអធិដ្ឋានរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្វាយព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ានៅឆ្នាំ ២០១៧ ខ្ញុំក៏បានថ្វាយពាក្យអធិដ្ឋាននេះទៅព្រះនាងម៉ារីនៅអរិយក្សេត្រ និងនៅថ្ងៃសុក្រពិសិដ្ឋកន្លងមក ពេលព្រះនាងម៉ារីរងទុក្ខលំបាកនៅក្បែរឈើឆ្កាងដែរ។ រួមជាមួយគ្នាយើងចូលនៅក្នុងការអធិដ្ឋាននេះ៖

## ពាក្យអធិដ្ឋានសម្រាប់ព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ា

បពិត្រព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាអើយ! ដោយយើងខ្ញុំលើកតម្កើងដល់ព្រះនាងម៉ារីដែលជាមាតារបស់យើងខ្ញុំ យើងខ្ញុំបញ្ចូលសំឡេងយើងតែមួយរួមជាមួយជំនាន់ទាំងឡាយ ដែលទទួលស្គាល់ថា ពិតមែនព្រះនាងម៉ារីមានសុភមង្គលហើយ។ យើងខ្ញុំរួមគ្នា កោតសរសើរស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់ព្រះនាងម៉ារី យើងនឹកឃើញព្រះបិតារបស់យើង ដែលប្រទានធម៌មេត្តាករុណាដល់មនុស្សលោក ជាពិសេសបានប្រមូលមនុស្សដែលពោរពេញដោយទុក្ខលំបាក ដែលពោរពេញដោយរបួសព្រោះតែអំពើបាប ដើម្បីព្យាបាលនិងដើម្បីសង្គ្រោះគេ។

បពិត្រព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាអើយ! សូមទទួលស្វាគមន៍ជីវិតរបស់យើងខ្ញុំ ដែលយើងខ្ញុំផ្ញើនៅថ្ងៃនេះ ដោយដឹងថាយើងទុកចិត្តលើព្រះនាង និងយើងទូលអង្វរព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាដែលនៅក្បែរយើង។ យើងខ្ញុំជឿថា ពិតមែនយើងទាំងអស់គ្នាយើងជាមនុស្សដែលមានសារៈសំខាន់ និងមានតម្លៃយ៉ាងខ្ពស់បំផុតនៅក្នុងជីវិតរបស់ព្រះជាម្ចាស់។ យើងខ្ញុំដឹងថា ព្រះអង្គស្រឡាញ់យើងយ៉ាងខ្លាំង និងព្រះអង្គធ្វើដំណើរជាមួយយើងជានិច្ច ដើម្បីឲ្យយើងខ្ញុំទទួលការលើកទឹកចិត្ត និងទទួលសេចក្ដីសង្ឃឹមសាជាថ្មី។

បពិត្រព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាអើយ! សូមទទួលស្វាគមន៍យើងខ្ញុំ សូមទទួលស្វាគមន៍ជីវិតរបស់យើងខ្ញុំ សូមប្រទានពរដល់ជីវិតរបស់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំទាំងអស់គ្នាយកចិត្តទុកដាក់ធ្វើតែអំពើល្អ ផ្ដល់កម្លាំងកាយកម្លាំងចិត្តដើម្បីឲ្យជំនឿរបស់យើងខ្ញុំរីកចម្រើនថែមទៀត។ លើកទឹកចិត្តយើងខ្ញុំ ដើម្បីឲ្យសេចក្ដីសង្ឃឹមរបស់យើងខ្ញុំរកឃើញពន្លឺសាជាថ្មី ផ្ដល់កម្លាំងកាយកម្លាំងចិត្តឲ្យយើងខ្ញុំ ដើម្បីឲ្យធម៌មេត្តាករុណាដឹកនាំជីវិតរបស់យើងខ្ញុំ និងឲ្យយើងខ្ញុំធ្វើដំណើររួមជាមួយព្រះនាងម៉ារីឆ្ពោះទៅជីវិតដ៏វិសុទ្ធ។

បពិត្រព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាអើយ! សូមណែនាំឲ្យយើងខ្ញុំចេះស្រឡាញ់គ្នាទៅវិញទៅមក ឲ្យយើងខ្ញុំចេះស្រឡាញ់មនុស្សតូចតាច អ្នកក្រីក្រ មនុស្សដែលគ្មានទីពឹង មនុស្សដែលសង្គមមើលមិនឃើញ ជាពិសេសមនុស្សបាប និងមនុស្សដែលវង្វេងផ្លូវនៅក្នុងសង្គមបច្ចុប្បន្ននេះ។

បពិត្រព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាអើយ! សូមការពារថែរក្សាយើងខ្ញុំទាំងអស់គ្នា ពិភពលោកទាំងមូល សង្គមកម្ពុជារបស់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំយកឈ្នះជំងឺកូវីដ១៩ដែលកំពុងបៀតបៀនយើងខ្ញុំ។

បពិត្រព្រះនាងម៉ារីនៃទីក្រុងហ្វាទីម៉ាអើយ! សូមអធិដ្ឋានសម្រាប់យើងខ្ញុំផង ជាពិសេសសម្រាប់បងប្អូនដែលកំពុងទទួលមរណភាពនៅក្នុងពេលវេលាដ៏បាកនេះ។ សម្រាប់ពិភពលោកទាំងមូល និងសម្រាប់ប្រទេសកម្ពុជា ព្រះនាងម៉ារីសូមជួយឲ្យយើងខ្ញុំថែរក្សាជំនឿរបស់យើងខ្ញុំយ៉ាងរឹងមាំ សេចក្ដីសង្ឃឹមរបស់យើងខ្ញុំ និងសេចក្ដីស្រឡាញ់របស់យើងខ្ញុំ។ សូមប្រមែប្រមូលយើងខ្ញុំទាំងអស់គ្នា ដែលជាកូនចៅរបស់ព្រះនាង ដើម្បីការពារថែរក្សាយើងខ្ញុំនៅក្នុងជីវិតដ៏បរិបូរណ៍របស់ព្រះយេស៊ូគ្រីស្តជាអម្ចាស់។

**យើងទូលអង្វរព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្តជាអម្ចាស់យើងខ្ញុំ**

## សូមព្រះអង្គម្ចាស់គង់នៅជាមួយបងប្អូន

តាមរយៈព្រះនាងម៉ារីជាមហាក្សត្រីនៃក្រុមគ្រីស្តទូត តាមរយៈសន្តយ៉ូសែបជាស្វាមីរបស់ព្រះនាង តាមរយៈក្រុមគ្រីស្តទូតទាំងឡាយ និងតាមរយៈសន្តសន្តីបុគ្គលទាំងអស់ សូមព្រះជាម្ចាស់ដ៏មានតេជានុភាពសព្វប្រការ គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ប្រទានព្រះពរឲ្យអស់បងប្អូន។ សូមអស់បងប្អូនអញ្ជើញឲ្យបានសុខសាន្ត និងរកឃើញសេចក្ដីសង្ឃឹមជានិច្ច! អាម៉ែន។